**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តកំពង់ចាម**

លេខ:...១២៣.../១៩.សជណ

# សេចក្តីជូនដំណឹង

## ស្តីពី

## ការអញ្ជើញចូលរួមដេញថ្លៃការទារជួសជុលរបងច្រកចូលអង្គភាពច្រកចេញចូលតែមួយ ចាក់កម្រាលសាបបេតុង រៀបសួនច្បារ អគារសាលប្រជុំ និងសាលសន្និសីទ ស្ថិតនៅក្នុងសាលាខេត្តកំពង់ចាម ជូនសាលាខេត្តកំពង់ចាម

រដ្ឋបាលខេត្តកំពង់ចាម: សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា: រដ្ឋបាលខេត្តកំពង់ចាម នឹងដាក់ឲ្យដេញថ្លៃជាសាធារណៈ ដើម្បីជ្រើសរើស**អ្នកទទួលការជួសជុលរបងច្រកចូលអង្គភាពច្រកចេញចូលតែមួយ ចាក់កម្រាលសាបបេតុង រៀបសួនច្បារ អគារសាលប្រជុំ និងសាលសន្និសីទ ស្ថិតនៅក្នុងសាលាខេត្តកំពង់ចាម ជូនសាលាខេត្តកំពង់ចាម។**

រដ្ឋបាលខេត្តកំពង់ចាម បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ។ ឯកសារដេញថ្លៃមានដាក់លក់នៅអង្គភាពលទ្ធកម្មសាលាខេត្ត ដែលមានអាសយដ្ឋាននៅភូមិទី៧ សង្កាត់កំពង់ចាម ក្រុងកំពង់ចាម ចាប់ពីថ្ងៃទី...២៨....ខែ...វិច្ឆិកា.....ឆ្នាំ២០១៩ តទៅរៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ: 042 211 144)។

ឯកសារដេញថ្លៃដែលបានបំពេញរួច ត្រូវប្រគល់ជូនអង្គភាពលទ្ធកម្មសាលាខេត្តកំពង់ចាម យ៉ាងយូរបំផុតត្រឹមថ្ងៃទី ...០៣....ខែ.ធ្នូ.....ឆ្នាំ២០១៩ វេលាម៉ោង...៩ព្រឹក០០.....។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្មសាលាខេត្តកំពង់ចាម តាមអាសយដ្ឋានខាងលើ វេលាម៉ោង ...៩ព្រឹក០០....ថ្ងៃទី...០៣....ខែ.ធ្នូ.....ឆ្នាំ២០១៩។

បានពិនិត្យត្រឹមត្រូវ

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយអាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្មសាលាខេត្ត ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មានដែលទាក់ទងនឹងការដេញថ្លៃនេះ។

ថ្ងៃ...១២កើត... ខែ.កត្តិក.. ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

កំពង់ចាម ថ្ងៃទី...១២.....ខែ.វិច្ឆិកា......ឆ្នាំ២០១៩

**អភិបាល នៃគណៈអភិបាលខេត្តកំពង់ចាម**

**និងជាប្រធានគណៈកម្មាធិការលទ្ធកម្ម**

<u>ចម្លងជូន</u>

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ)
- អង្គភាពប្រឆាំងអំពើពុករលួយ

"<u>ដើម្បីជូនជ្រាប</u>"

- ឯកសារ-កាលប្បវត្តិ